# <u>សេចក្តីប្រកាសព័ត៌មានស្តីពី</u>

## លទ្ធផលនៃទស្សនៈកិច្ចផ្លូវការរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ពីថ្ងៃទី ២៦-៣០ ខែមីនា ឆ្នាំ២០១៦




កាលពីថ្ងៃទី ២៦ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ បានដឹកនាំគណៈប្រតិភូ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មួយក្រុមអញ្ជើញ ទៅបំពេញទស្សនៈកិច្ចជាផ្លូវការនៅរដ្ឋធានីហាណូយនៃប្រទេសវៀតណាម ។




ជាលទ្ធផល នៅថ្ងៃទី២៨ ខែ មីនាឆ្នាំ ២០១៦ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងគណៈប្រតិភូបានជួបប្រជុំ ទ្វេភាគីជាមួយឯកឧត្តម Vu Huy Hoang រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម នៃប្រទេសវៀតណាម


H.E CHAM Prasidh


Ms. Le Hoang Oanh
Director General
Asia - Pacific Market Department
H.E. Mr.Vu Huy Hoang
Minister of Industry and Trade

ក្នុងកិច្ចប្រជុំនោះ ភាគីទាំងពីរ បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មរវាងប្រទេសកម្ពុជា វៀតណាម ដើម្បីជំរុញអភិវឌ្ឍវិស័យនេះ តាមរយៈលើកកម្ពស់ការទាក់ទាញអ្នកវិនិយោគ ដើម្បីបង្កើនការងារ និងសេដ្ឋកិច្ចមានចីរភាព ។ ដូច្នេះប្រទេសទាំងពីរ គួរស្វែងរកយន្តការណាសមស្របមាន ដូចជា៖ សម្របសម្រួលគម្រោងវិនិយោគឱ្យមានការរីកចម្រើន- សិក្សាស្រាវជ្រាវអំពីការកាត់បន្ថយពន្ធត្រួតគ្នា- ចែករំលែកព័ត៌មាន បទពិសោធន៍គ្នាទៅវិញទៅមកពាក់ព័ន្ធនឹងច្បាប់ បទប្បញ្ញាតសម្រាប់ការវិនិយោគ ដែលប្រទេសទាំងពីរមានភាពខុសគ្នា ដោយគួរបង្កើតក្រុមសិក្សាមួយ ស្រាវជ្រាវរៀបចំច្បាប់ឱ្យដូចគ្នា ដើម្បីបង្ក លក្ខណៈងាយស្រួលដល់ការវិនិយោគអោយកាន់តែមានភាពរលូន។ ដៃគូសន្ទនា បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើឧស្សាហកម្មវាយនភ័ណ្ឌ៖ អង្គប្រជុំបានផ្លាស់ប្តូរព័ត៌មានគ្នាអំពីការនាំចេញផលិតផលឧស្សាហកម្មវាយនភ័ណ្ឌ រួមមាន ប្រទេសអាមេរិក និងប្រទេសអឺរ៉ុប។ ប្រទេសវៀតណាមមានលំដាប់ថ្នាក់ទី២ក្នុងការនាំចេញទៅសហរដ្ឋអាមេរិក ដែលប្រទេសកម្ពុជាមានលំដាប់ថ្នាក់ទី៨ ប៉ុន្តែការនាំចេញទៅអឺរ៉ុបវិញ ប្រទេសកម្ពុជាមានលំដាប់ថ្នាក់ទី៥ ប្រទេសវៀតណាមមានលំដាប់ថ្នាក់ទី៦ ។ ជាមួយគ្នានេះ ភាគីទាំងពីរក៏ បានផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការវិស័យពាណិជ្ជកម្ម ស្តីពីការផ្លាស់ប្តូរទំនិញតាមព្រំដែន ដោយបង្ហាញជំហរថាកិច្ចព្រមព្រៀងឆ្នាំ១៩៩៣-២០០១ គួរពិនិត្យលទ្ធភាពផ្លាស់ប្តូររៀបចំធ្វើបច្ចុប្បន្នភាពឡើងវិញ តាមស្មារតីកិច្ចប្រជុំកាលពីឆ្នាំ២០១២-២០១៣ ដែលបានសំណូមពរសុំឱ្យមានការផ្លាស់ប្តូរ។ ប៉ុន្តែកន្លងទៅរយៈពេល ៣ ឆ្នាំ សេចក្តីព្រាងកិច្ចព្រមព្រៀងនេះមិនទាន់អនុម័តនៅឡើយ ។ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ មាន ការកើនឡើងតិចតួច ក្នុងឆ្នាំ២០១៤ បានតែ ២០០០លានដុល្លាអាមេរិក ដែលមានគម្លាតឆ្ងាយពីផែនការ មានទំហំ ៥០០០លានដុល្លាអាមេរិកនៅឆ្នាំ២០១៥ ។ បញ្ហានេះ ភាគីទាំងពីរបានផ្តល់សារៈសំខាន់ ទៅលើចំណុចចាំបាច់មួយចំនួនមានដូចជា៖-ពិនិត្យលទ្ធភាពរៀបចំគម្រោងបើកច្រកនិងបង្កើតទីផ្សារតំបន់ដែលមានសក្តានុពលតាមព្រំដែនឲបានកាន់តែច្រើន ដើម្បីឆ្លើយតបនិងតម្រូវការ ជាពិសេសក្រោមក្របខ័ណ្ឌសមាហ រណកម្មអាស៊ាន - ការកាត់បន្ថយការចំណាយដឹកជញ្ជូនទំនិញ និងសម្រួលបែបបទពន្ធគយជាដើម។


BETWEEN
OF INDUSTRY AND TRADE OF THE
AND
SENIOR
, MINISTER OF
HANDIC
28th



នៅថ្ងៃទី២៨ ខែ ឆ្នាំ ដដែល ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងគណៈប្រតិភូអមដំណើរបាន ជួបសំដែងការគួរសមជាមួយឯកឧត្តម Vu Duc Dam ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីនៃ ប្រទេសវៀតណាម ។



នៅអំឡុងការសំដែងការគួរសម ភាគីទាំងពីរបានរំលឹកពីប្រវត្តិនៃកិច្ចសហប្រតិបត្តិការដ៏យូរលង់កន្លង ក្នុងនាមជាប្រទេសជិតខាង តែងតែជួយគ្នាទៅវិញទៅមកក្នុងក្របខណ្ឌជាតិក៏ដូចជាក្នុងតំបន់ ដើម្បីអភិវឌ្ឍ ប្រទេស។ ឯកឧត្តម Vu Duc Dam ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក៏បានផ្តាំផ្ញើសួរ សុខទុក្ខជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណា ចក្រកម្ពុជា** ដែលជានិច្ចជាកាលមានកិច្ចសហប្រតិបត្តិការដ៏ជិតស្និតលើគ្រប់វិស័យជាមួយប្រទេសវៀតណាម ។



ភាគីទាំងពីរបានរិះរកវិធានការក្នុងការពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការសម្រាប់ថ្ងៃអានាគត ដើម្បីដណ្តើមទីផ្សារក្នុង និងក្រៅតំបន់ ក៏ដូចជាបង្កើនការនាំចេញ ។ ភាគីទាំងពីរមានសំណូមពរ ពង្រឹងសន្តិសុខសុវត្ថិភាព ស្ថេរភាពតាមព្រំដែន និងបើកច្រកឱ្យបានច្រើនបន្ថែមទៀត ដើម្បីសហការអភិវឌ្ឍទាំងអស់គ្នា ។



ដោយឡែកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និង គណៈប្រតិ ភូអម ដំណើរបាននៅទស្សនៈកិច្ចនៅសួនឧស្សាហកម្ម វៀតណាម-សឹង្ហបូរី (Vietnam Singapore Industry Park:VSIP)ដែលសួនឧស្សាហកម្ម វៀតណាម-សឹង្ហបូរី នេះ បានបង្កើតឡើងតាំងពីឆ្នាំ១៩៩៦ ផ្តួចផ្តើម ដោយអតីតនាយករដ្ឋមន្ត្រី នៃប្រទេសទាំងពីរ ឯកឧត្តម Goh Chok Tong និង ឯកឧត្តម Vo Van Kiet ក្រោម រូបភាពវិនិយោគរួមគ្នា ប្រទេសវៀតណាម ៥១% និង សឹង្ហបូរី ៤៩%។ សួនឧស្សាហកម្មនេះទទួលបានលទ្ធ ផលជោគជ័យក្នុងចំណោមសួនឧស្សាហកម្មផ្សេងទៀតនៅប្រទេសវៀតណាម បានបង្កើតការងារ ជាច្រើន ដល់ប្រជាជន លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅជុំវិញតំបន់នោះ បង្កើនបានកំណើន សេដ្ឋកិច្ចក្នុង តំបន់ និងទាក់ទាញបានអ្នកវិនិយោគមកពី ២២ប្រទេស ដែលទទួលបានការលើកទឹកចិត្តតាមរយៈការ អនុគ្រោះពន្ធ។ កម្មករត្រូវបានបណ្តុះបណ្តាលនៅប្រទេសសឹង្ហបូរី ដើម្បីបង្កើនជំនាញបច្ចេកទេស ហើយអាច




ទទួលបានបៀវត្សរ៍កាន់តែខ្ពស់ ។




ស្ថិតក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ សមិទ្ធិផលរួមគ្នារវាងវៀតណាមនិងសឹង្ហបុរី និងក៏ជាបទពិសោធន៍សម្រាប់កម្ពុជាផងដែរ ។



ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងលោកជំទាវនិងប្រតិភូអមដំណើរ បានអញ្ជើញវិលត្រឡប់មកមាតុប្រទេសវិញប្រកបដោយសុវត្ថិភាព និងលទ្ធផលផ្លែផ្កា នៅរសៀលថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៦ តាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។